# កម្មវិធីបង្វិលប្រាក់សំណងកែលំអអាគារពាណិជ្ជកម្ម

***តើអ្វីជាកម្មវិធីបង្វិលប្រាក់សំណងកែលំអអាគារពាណិជ្ជកម្ម ?***

គឺជាកម្មវិធីមួយដែលផ្តល់ប្រាក់សំណងរហូតដល់ទៅ ***$2,000 ក្នុងមួយហាងជំនួញ*** ទៅឲ្យម្ចាស់អាគារពាណិជ្ជកម្មនិងម្ចាស់ហាងជំនួញ ដើម្បីកែលម្អផ្នែកខាងក្រៅ និង ឬ ដើម្បីកែតម្រូវការបំពានលើច្បាប់អាគារផ្សេងៗនៃអាគារពាណិជ្ជកម្មរបស់គេ។

***តើនរណាមានសិទ្ធិអាចទទួលបាន ?***

ម្ចាស់អាគារពាណិជ្ជកម្មនិងម្ចាស់ហាងជំនួញដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍សហគមន៍ដែលជ្រើសតាំងដោយក្រសួងសហព័ន្ធ (CDBG) *(សូមមើលផែនទីនៅខាងខ្នងសម្រាប់ភាពមានសិទ្ធិទទួលបាន)* ។

ផ្លូវនានាខាងក្រោម អាចមានសិទ្ធិទទួលបានកម្មវិធីនេះ៖

4th St. – Los Angeles River to Elm Ave. & Atlantic Ave. to Grand Ave.
7th St. - Los Angeles River to Park Ave.
10th St. – Los Angeles River to Park Ave.
Alamitos Ave. - Ocean Blvd. to Pacific Coast Hwy.
Anaheim St. – West City Limit to Pacific Coast Hwy.
Artesia Blvd. - West City Limit to East City Limit
Atlantic Ave. - Ocean Blvd to Spring St. & Wardlow Rd. to 36th St. & 46th St. to North City Limit
Broadway – Los Angeles River to Elm Ave. & Atlantic Ave. to Junipero Ave.
Cherry Ave. – 1st St. to 19th St. & Carson St. to Del Amo Blvd. & Jackson St. to 70th St.
Long Beach Blvd. – Broadway to Spring St. & Wardlow Rd. to 36th St. & 46th St. to North City Limit
Magnolia Ave. – Broadway to Burnett St. & Willow St. to 27th St.
Market St. - Los Angeles River to Orange Ave. & Walnut Ave. to East City Limit
Pacific Ave. – Broadway to 27th St. & 28th St. to Spring St. & Wardlow Rd. to 36th St. & 48th St. to Los Angeles River
Pacific Coast Hwy. – West City Limit to Clark Ave.
Paramount Blvd. – Candlewood St. to North City Limit
Pine Ave. – Broadway to 27th St.
Santa Fe Ave. – Anaheim St. to 405 Freeway
South St. - Los Angeles River to Downey Ave.
Willow St. – West City Limit to Olive Ave.

***តើខ្ញុំដាក់ពាក្យដោយរបៀបណា ?***

អ្នកត្រូវបំពេញពាក្យស្នើសុំហើយដាក់ជូនទៅបុគ្គលិកបំរើកិច្ចការក្នុងភូមិ (Neighborhood Services)។ នៅពេលទទួលពាក្យដែលបំពេញរួចរបស់អ្នក ភាពជាម្ចាស់កម្មសិទ្ធិនៃអាគារពាណិជ្ជកម្មរបស់អ្នកនឹងត្រូវបានគេផ្ទៀងផ្ទាត់ ហើយភាពមានសិទ្ធិទទួលបានត្រូវបានកំណត់តាមក្រោយ។ បើអ្នកមានលក្ខណៈភាពអាចទទួលបាន គេនឹងផ្ញើរប័ណ្ណយល់ស្របអនុញ្ញាត្តិឱ្យអ្នកបន្តកិច្ចការកែលំអផ្សេងៗ។

***សូមចំណាំ៖*** អាគារបានសាងសង់មុនឆ្នាំ 1940 ត្រូវតម្រូវតាមការអនុម័តលើផ្នែកបរិស្ថានដោយរដ្ឋកាលីហ្វ័រញ៉ា មុនពេលប័ណ្ណយល់ព្រមអាចនឹងចេញជូន។

CIRP Flyer 08-16 - Khmer

ដំណើរការនេះអាចចំណាយពេលពីពីរទៅបីខែដើម្បីបញ្ចប់។ **សូមកុំទាន់ទិញសម្ភារៈណាមួយឬចាត់ចំណាត់ការណាឱ្យសោះ រហូតទាល់តែអ្នកបានទទួលប័ណ្ណយល់ព្រមសិន។**

***តើប្រភេទកែលម្អអ្វីខ្លះអាចមានសិទ្ធិទទួលបាន ?***

ការកែតម្រូវផ្នែកខាងក្រៅនៃអាគារពាណិជ្ជកម្មដែលមើលឃើញពីផ្លូវថ្នល់អាចទាក់ទងទៅនឹងច្បាប់សុខភាពរបស់ក្រុង ច្បាប់អាគារ និងសុវត្ថិភាព។

***នៅពេលការងារបានបញ្ចប់ តើរាប់ប៉ុណ្ណាខ្ញុំនឹងបានទទួលសែកប្រាក់បង្វិលសងមកវិញ ?***

បុគ្គលិកក្រុងនឹងចាត់ចែងកិច្ចការនេះ ហើយនឹងផ្ញើរសែកប្រាក់បង្វិលសងទៅអ្នកក្នុងរយៈពេលពី ៤ ទៅ ៦ អាទិត្យ បន្ទាប់ពីបានទទួលតម្រូវបង្កាន់ដៃនិងវិក្ក័យបត្រ (Receipts and Invoices) និងវិក្ក័យបត្របំពេញត្រឹមត្រូវពីម្ចាស់អាគារ ឬ ម្ចាស់ហាងជំនួញ (Completed Owner Invoice) ។




## **សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅលេខ (562) 570-6866**

ព័ត៌មាននេះអាចរកបានក្នុងទម្រង់ផ្សេងទៀតដោយស្នើទៅ នៅលេខ (562) 570-3807